# ផែនការយុទ្ធសាស្ត្រ ០៥ឆ្នាំ
# ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧
# របស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

## ១. សេចក្តីផ្តើម

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប (Asia Euro University) ជាសាកលវិទ្យាល័យមួយ ដែលដើមឡើយ គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ដែលបានចាប់បដិសន្ធិ និងដំណើរការចាប់ពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០២ ដែលមានឈ្មោះថា **អង្គការវិទ្យាស្ថាន អាស៊ី អឺរ៉ុប** មានការទទួលស្គាល់តាមលិខិតលេខ១៣៤១ សជណ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ របស់ក្រសួងមហាផ្ទៃ។ ក្នុងឆ្នាំដដែលនេះ អង្គការវិទ្យាស្ថាន អាស៊ី អឺរ៉ុប ក៏បានវិវឌ្ឍន៍ខ្លួនជា **វិទ្យាស្ថាន អាស៊ី អឺរ៉ុប** តាមប្រកាសលេខ៩០២ អយក.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ របស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបណ្តុះបណ្តាលលើថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស និងថ្នាក់វិញ្ញាបនបត្រ។ បន្ទាប់មកដោយមានការកើនឡើងនូវចំនួននិស្សិត និងមានលទ្ធភាពគ្រប់គ្រាន់នោះវិទ្យាស្ថានអាស៊ី អឺរ៉ុប (Asia Euro Institute) ត្រូវបានអនុញ្ញាតឱ្យធ្វើការបណ្តុះ បណ្តាលរហូតដល់កម្រិតបរិញ្ញាបត្រ តាមអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃ ទី២២ ខែឧសភា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ អាស្រ័យដោយការបណ្តុះបណ្តាលកាន់តែមានទំហំធំទៅៗ និងដោយមានការគាំទ្រកាន់តែច្រើនពីសំណាក់សិស្ស-និស្សិតផង ពិសេសដើម្បីឱ្យស្របនឹងទិសដៅនៃការអភិវឌ្ឍរបស់ប្រទេសជាតិផងនោះវិទ្យាស្ថានអាស៊ី អឺរ៉ុប ក៏អភិវឌ្ឍន៍ប្រែក្លាយខ្លួនទៅជា **សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប** (Asia Euro University) តាមអនុក្រឹត្យលេខ០៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងអប់រំ យុវជន និងកីឡា ដោយធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររងរហូតដល់ថ្នាក់បណ្ឌិត។

តាំងពីពេលចាប់ផ្តើម រហូតមកដល់បច្ចុប្បន្ន និងទៅអនាគត សាកលវិទ្យាល័យតែងតែបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អភិវឌ្ឍនូវកម្មវិធីសិក្សា និងការស្រាវជ្រាវ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងសង្គម ដោយបញ្ចូលឱ្យមានការអប់រំផ្នែកឯកទេស ជំនាញ ការអប់រំផ្នែកគុណធម៌ និងការអប់រំផ្នែកកាយសម្បទា ឱ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងតាមការធ្វើកំណែទម្រង់វិស័យឧត្តមសិក្សា ជាពិសេសគោលនយោបាយស្តីពី *ចក្ខុវិស័យឧត្តមសិក្សា ២០៣០* របស់ក្រសួងអប់រំ យុវជន និងកីឡា។ ជាមួយគ្នានេះដែរ ដោយកិច្ចខិតខំប្រឹងប្រែងប្រកបដោយភាពជោគជ័យ និងមានគុណភាពផងនោះ សាកលវិទ្យាល័យ ក៏ត្រូវបានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាធ្វើការវាយតម្លៃ និងទទួលស្គាល់គុណភាពនៃការបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ជាប់ពេញសិទ្ធិជាលើកទី២ រយៈពេល០៣ឆ្នាំ តាមរយៈលិខិតលេខ ១៤២/១៣ គ.ទ.ក.ស.ជ.ណ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣។

## ២. ចក្ខុវិស័យ បេសកកម្ម វត្ថុបំណង និងឧត្តមភាពរបស់សាកលវិទ្យាល័យ

### ២.១. ចក្ខុវិស័យ

ប្រែក្លាយជាសាកលវិទ្យាល័យមួយ ដែលមានឧត្តមភាព កិត្យានុភាព និងផលិតភាពក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងការស្រាវជ្រាវ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការ

ការសិក្សា និងការងាររដ្ឋបាល ដែលជាការផ្តល់សេវាមួយមានទិសដៅឆ្ពោះទៅរកការបង្កើន សមត្ថភាពធនធានមនុស្ស សម្រាប់បម្រើការក្នុងទីផ្សារការងារទាំងក្នុង និងទាំងក្រៅប្រទេស។

### ២.៤.៤. តម្លាភាព និងភាពមិនលំអៀង

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប មានតម្លាភាពលើការវាយតម្លៃការសិក្សារបស់និស្សិត គ្រប់ជំនាញ ជំនាន់ ក៏ដូចជាការអភិវឌ្ឍ និងលើកទឹកចិត្តបុគ្គលិកក្នុងការចូលរួមផ្តល់មតិយោបល់លើដំណើរការបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យ។

### ២.៤.៥. សហប្រតិបត្តិការ

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប បាននឹងបន្តធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធភាពព្រមទាំងពង្រឹង និងពង្រីកនូវភាពជាដៃគូជាមួយស្ថាប័នរដ្ឋ និងឯកជន អង្គការក្នុង និងក្រៅរដ្ឋាភិបាល សាកលវិទ្យាល័យនានាទាំងនៅក្នុង និងក្រៅប្រទេស ដើម្បីសម្រេចឱ្យបាននូវបេសកកម្ម និងចក្ខុវិស័យរបស់ខ្លួន។

### ២.៤.៦. ការទទួលខុសត្រូវ

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប បំពេញកាតព្វកិច្ចរបស់ខ្លួន ដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខរាជរដ្ឋាភិបាល សង្គមជាតិ អាណាព្យាបាលរបស់និស្សិត និងដៃគូសហការ។

## ៣. បាវចនារបស់សាកលវិទ្យាល័យ

| គុណភាព | សុចរិតភាព | ភាពលទ្ធភាព |
|---|---|---|
| Quality | Integrity | Opportunity |

## ៤. គុណតម្លៃរបស់សាកលវិទ្យាល័យ

*ធ្វើឱ្យការអប់រំកាន់តែប្រសើរ* (Advance Education)

*ថ្លៃសិក្សាសមរម្យ* (Economic Fee)

*លើកកម្ពស់អាជីពរបស់អ្នក* (Uplift Your Career)

## ៥. យុទ្ធសាស្រ្ត ២០២៣-២០២៧

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប បានផ្តោតសំខាន់លើយុទ្ធសាស្រ្តចំនួន ៦ សម្រាប់រយៈពេល ៥ឆ្នាំ របស់ខ្លួនដូចខាងក្រោម ៖

ក. យុទ្ធសាស្រ្តទី១ ៖ អភិបាលកិច្ច

គោលដៅទី១ : ការចូលរួម និងការវាយតម្លៃ

គោលដៅទី២ : តម្លាភាព

គោលដៅទី៣ : ផែនការ និងគោលនយោបាយ

ខ. យុទ្ធសាស្រ្តទី២ ៖ អភិវឌ្ឍន៍ស្ថាប័ន

គោលដៅទី១ : រដ្ឋបាល

គោលដៅទី២ : ធនធានមនុស្ស

គោលដៅទី៣ : ហិរញ្ញវត្ថុ

គ. យុទ្ធសាស្រ្តទី៣ ៖ ការរៀន និងការបង្រៀន

គោលដៅទី១ : កម្មវិធីសិក្សា

គោលដៅទី២ : គ្រូបង្រៀន

គោលដៅទី៣ : និស្សិត

ឃ. យុទ្ធសាស្ត្រទី៤ ៖ ការងារនិស្សិត

គោលដៅទី១ : ផ្តល់ព័ត៌មាន និងការងារ

គោលដៅទី២ : តម្រូវការទីផ្សារ

គោលដៅទី៣ : ដៃគូទទួលនិស្សិត

ង. យុទ្ធសាស្ត្រទី៥ ៖ ការស្រាវជ្រាវ

គោលដៅទី១ : មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ (RDC)

គោលដៅទី២ : ធនធានស្រាវជ្រាវ

គោលដៅទី៣ : ការបោះពុម្ពផ្សាយ

ច. យុទ្ធសាស្ត្រទី៦ ៖ ការកសាងសមត្ថភាព និងនវានុវត្តន៍ឌីជីថល

គោលដៅទី១ : កសាងមូលធនឌីជីថល

គោលដៅទី២ : លើកកម្ពស់ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល

គោលដៅទី៣ : ការរៀបចំកិច្ចសហការនិងភាពជាដៃគូជាមួយស្ថាប័នបច្ចេកវិទ្យាឌីជីថល




គំនូសបំព្រួញផែនការយុទ្ធសាស្ត្រ ២០២៣-២០២៧

## យុទ្ធសាស្ត្រទី១ ៖ អភិបាលកិច្ច

អភិបាលកិច្ច ជាយុទ្ធសាស្ត្រគោលទី១ សម្រាប់ជាយន្តការជំរុញប្រសិទ្ធភាពដល់យុទ្ធសាស្ត្រទាំង៥ទៀត។ សាកលវិទ្យាល័យបានកំណត់ថាអភិបាលកិច្ច គឺយន្តការនៃអភិក្រមស្ថាប័នទាំងមូល ដែលសំដៅទៅដល់ការដឹកនាំ ការគ្រប់គ្រង និងចាត់ចែងនូវរាល់កម្មវិធីការងារ គ្រប់កម្រិតរបស់ខ្លួន ដោយផ្អែកលើវិធីសាស្ត្រសំខាន់ៗ រួមមាន ការចូលរួម តម្លាភាព ការរៀបចំផែនការដាក់លាក់ គោលការណ៍ និងគោលនយោបាយ និងការតាមដានវាយតម្លៃ។

| យុទ្ធសាស្ត្រ | លទ្ធផលរំពឹងទុក |
|---|---|
| **អភិបាលកិច្ច** | - សាកលវិទ្យាល័យ នឹងទទួលបានការចូលរួម និងវាយតម្លៃក្នុងការរៀបចំការគ្រប់គ្រង និងធ្វើអភិបាលកិច្ច ក្នុងស្ថាប័នដោយបុគ្គលិក និងដៃគូអភិវឌ្ឍន៍បានគ្រប់ជ្រុងជ្រោយ។<br>- សាកលវិទ្យាល័យ នឹងទទួលបានព័ត៌មានទាំងឡាយក្នុងការរៀបចំនូវគោលការណ៍ ផែនការការងារ ផែនការរដ្ឋបាល និងហិរញ្ញវត្ថុជាក់លាក់ ហើយនឹងទទួលបាននូវឯកសារគាំទ្រច្បាស់លាស់ គ្រប់គ្រាន់។<br>- សាកលវិទ្យាល័យ នឹងទទួលបាននូវផែនការ និងគោលនយោបាយមួយសមស្រប ត្រឹមត្រូវ ស្របតាមនិន្នាការសង្គមជាតិ នាពេលបច្ចុប្បន្ន ក្នុងនោះរួមមាន ផែនការយុទ្ធសាស្ត្រ និងផែនការ សកម្មភាពរបស់សាកលវិទ្យាល័យទាំងមូល ក៏ដូចជារបស់មហាវិទ្យាល័យទាំងអស់ និងអង្គភាពចំណុះ។ |

### គោលដៅទី១ ៖ ការចូលរួម និងការវាយតម្លៃ

ការចូលរួម និងវាយតម្លៃ គឺជាគោលដៅដ៏សំខាន់មួយ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រទី១ ស្តីពីអភិបាលកិច្ច។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ត្រូវចូលរួមកម្មវិធីតាមការអញ្ជើញរបស់គណៈគ្រប់គ្រង
- ត្រូវត្រៀមលក្ខណៈឱ្យបានរួចរាល់ដើម្បីបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព
- ត្រូវអនុវត្តនូវភារកិច្ចរបស់ខ្លួន ដោយការវាយតម្លៃនូវផែនការរបស់ខ្លួនដែលបានដាក់ចេញ។

### គោលដៅទី២ ៖ តម្លាភាព

តម្លាភាព ក៏ជាគោលដៅដ៏សំខាន់មួយដែរ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រទី១ ស្តីពីអភិបាលកិច្ច។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ត្រូវមានភាពស្មោះត្រង់ក្នុងការអនុវត្តការងារជូនស្ថាប័ន
- ត្រូវគោរពវិន័យ និងក្រមសីលធម៌ ហើយត្រូវអនុវត្តការងារជាប្រព័ន្ធតាមលំហូរការងារ និងឋានានុក្រម

- ធ្វើការផ្សព្វផ្សាយជាប្រចាំគ្រប់ព្រឹត្តិការណ៍ និងសកម្មភាពផ្សេងរបស់សាកលវិទ្យាល័យ ជូនដល់និស្សិត គ្រូបង្រៀន ដៃគូអភិវឌ្ឍន៍ ទាក់ទងគោលការណ៍សំខាន់ៗ ដូចជា ការប្រជុំគម្រោងថវិកា សវនកម្ម ការធ្វើសេចក្តីសម្រេចចិត្តនានា ដោយមានឯកសារគាំទ្រច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងនូវគណនេយ្យភាពការងាររបស់ខ្លួន។

### គោលដៅទី៣ ៖ ផែនការ និងគោលនយោបាយ

ផែនការ និងគោលនយោបាយ គឺជាគោលដៅដ៏សំខាន់មួយទៀត ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រទី១ ស្តីពីអភិបាលកិច្ច។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ត្រូវរៀបចំផែនការទីផ្សារ ហិរញ្ញវត្ថុ និងផ្នែកប្រតិបត្តិការឱ្យបានច្បាស់លាស់
- ត្រូវយល់ដឹងអំពីចក្ខុវិស័យរបស់ស្ថាប័ន
- ត្រូវរៀបចំផែនការរយៈពេលវែង ខ្លី ស្របតាមចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា និងស្របតាមការវិវឌ្ឍរបស់ប្រទេសជាតិ។

## យុទ្ធសាស្ត្រទី២ ៖ អភិវឌ្ឍន៍ស្ថាប័ន

អភិវឌ្ឍន៍ស្ថាប័ន ជាយុទ្ធសាស្ត្រគាំទ្រដល់ការជំរុញឱ្យសម្រេចបាននូវលទ្ធផលនៃយុទ្ធសាស្ត្រទាំងបីខាងលើ។ អភិវឌ្ឍន៍ស្ថាប័ន សំដៅលើការធ្វើឱ្យប្រសើរឡើង ឬបង្កើនវឌ្ឍនភាព គុណភាពការងាររបស់បុគ្គលិក និងការកែលម្អរចនាសម្ព័ន្ធការងារនៅគ្រប់កម្រិតរបស់សាកលវិទ្យាល័យ។ ក្នុងន័យនេះ សាកលវិទ្យាល័យបានកំណត់ថា ផ្នែករដ្ឋបាល ផ្នែកធនធានមនុស្ស និងផ្នែកហិរញ្ញវត្ថុ ជាចំណែកសំខាន់សម្រាប់ធ្វើការអភិវឌ្ឍស្ថាប័ន។

| យុទ្ធសាស្ត្រ | លទ្ធផលរំពឹងទុក |
|---|---|
| **អភិវឌ្ឍន៍ស្ថាប័ន** | - សាកលវិទ្យាល័យ នឹងទទួលបាននូវការគ្រប់គ្រងរដ្ឋបាលមួយច្បាស់លាស់ ដែលមានគោលនយោបាយរចនាសម្ព័ន្ធ និងការគ្រប់គ្រងមួយដ៏ត្រឹមត្រូវ។<br>- សាកលវិទ្យាល័យ នឹងទទួលបាននូវបុគ្គលិកមួយដែលប្រកបដោយវិជ្ជាជីវៈ មានមនសិការខ្ពស់ ជាផ្នែកសំខាន់របស់សាកលវិទ្យាល័យ ឬរបស់ស្ថាប័ន ក្នុងនោះមានទាំងបុគ្គលិកអប់រំ និងបុគ្គលិករដ្ឋបាលផងដែរ។<br>- សាកលវិទ្យាល័យ នឹងមានកញ្ចប់ថវិកា ឬមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមួយច្បាស់លាស់ ដើម្បីបញ្ចៀសបាននូវហានិភ័យរបស់សាកលវិទ្យាល័យ ក្នុងនោះ សាកលវិទ្យាល័យ នឹងទទួលបាននូវផែនការថវិកាពីគ្រប់មហាវិទ្យាល័យ និងអង្គភាពចំណុះគ្រប់គ្រាន់ប្រកបដោយប្រសិទ្ធភាព ហើយមានការចាយវាយទៅវិញ ប្រកបដោយវិចារណកម្មចំណាយ។ |

### គោលដៅទី១ ៖ រដ្ឋបាល

រដ្ឋបាល គឺជាគោលដៅមួយនៃយុទ្ធសាស្ត្រទី២ ស្តីពី អភិវឌ្ឍន៍ស្ថាប័ន។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ រចនាសម្ព័ន្ធ កិច្ចសន្យាបុគ្គលិក និងបែងចែកតួនាទីភារកិច្ចក្នុងការគ្រប់គ្រងតាមការិយាល័យ មហាវិទ្យាល័យនីមួយៗស្របតាមតម្រូវការជាក់ស្តែង
- គ្រប់គ្រង និងសម្របសម្រួលច្រកចេញចូលឯកសារបានត្រឹមត្រូវ សុវត្ថិភាព និងទាន់ពេលវេលា
- រៀបចំនូវគំរូឯកសារផ្សេងៗឱ្យស្របតាមស្តង់ដាទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

### គោលដៅទី២ ៖ ធនធានមនុស្ស

ធនធានមនុស្ស គឺជាគោលដៅសំខាន់មួយទៀតនៃយុទ្ធសាស្ត្រទី២ ស្តីពី អភិវឌ្ឍន៍ស្ថាប័ន។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលបុគ្គលិកឱ្យមានគុណវុឌ្ឍិគ្រប់គ្រាន់ស្របតាមតួនាទីនីមួយៗដើម្បីអនុវត្តការងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងមានមនសិការខ្ពស់
- ប្រជុំណែនាំ និងមានការត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងាររបស់បុគ្គលិកគ្រប់លំដាប់ថ្នាក់ជាប្រចាំ
- លើកទឹកចិត្តដល់បុគ្គលិក តាមរយៈរូបភាពផ្សេងៗ។

### គោលដៅទី៣ ៖ ហិរញ្ញវត្ថុ

ហិរញ្ញវត្ថុ គឺជាគោលដៅដ៏សំខាន់ចុងក្រោយនៃយុទ្ធសាស្ត្រទី២ ស្តីពី អភិវឌ្ឍន៍ស្ថាប័ន។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការហិរញ្ញវត្ថុច្បាស់លាស់សម្រាប់អនុវត្តតាមសកម្មភាពនីមួយៗ
- បង្កើតវិធីសាស្ត្រសម្រាប់ប្រមូលចំណូលដែលបានពីប្រភពផ្សេងៗ
- បង្កើតយន្តការទូទាត់ការចាយវាយប្រកបដោយតម្លាភាព។

## យុទ្ធសាស្ត្រទី៣ ៖ ការរៀន និងការបង្រៀន

ការរៀន និងការបង្រៀន ជាយុទ្ធសាស្ត្រសំខាន់ទី៣ សម្រាប់ទ្រទ្រង់នូវបេសកកម្មជាសារវន្តរបស់សាកលវិទ្យាល័យ។ សាកលវិទ្យាល័យបានកំណត់ថា ការសិក្សា (រៀន) របស់និស្សិតជាការងារអាទិភាពក្នុងអាទិភាពរបស់ខ្លួន។ និស្សិតមិនត្រឹមតែជាអតិថិជនប៉ុណ្ណោះទេ តែជាធនធានដ៏វិសេសវិសាលរបស់ខ្លួន។ ដូចនេះនិស្សិតទាំងអស់ដែលមកទទួលសេវាអប់រំនៅទីនេះ ត្រូវទទួលបាននូវការសិក្សាមួយប្រកបដោយគុណភាព សមធម៌ ទាន់សម័យ និងសម្បូរបែប តាមរយៈការបង្រៀនរបស់គ្រូដែលមានសមត្ថភាព ទេពកោសល្យ ជំនាញ វិជ្ជាជីវៈ និងក្រមសីលធម៌ ដោយមានកម្មវិធីសិក្សាទំនើបជាត្រីវិស័យតម្រង់ទិស។

| យុទ្ធសាស្ត្រ | លទ្ធផលរំពឹងទុក |
| --- | --- |
| ការរៀន និងការបង្រៀន | - សាកលវិទ្យាល័យ នឹងទទួលបាននូវកម្មវិធីសិក្សាមួយដែលមានគុណភាព ហើយរៀបចំ ឬអនុម័តឡើងដោយគណៈកម្មការ ដែលមានជំនាញច្បាស់លាស់ ហើយកម្មវិធីនោះ នឹងទទួលបានការធ្វើបច្ចុប្បន្នភាពជាប្រចាំ ទៅតាមពេលវេលាសមស្រប និងតាមបច្ចេកទេសគរុកោសល្យត្រឹមត្រូវ។<br>- សាកលវិទ្យាល័យ នឹងទទួលបាននូវគ្រូបង្រៀនមួយដែលមានសមត្ថភាព និងចេះប្រើប្រាស់ ICT ក្នុងការបង្រៀន មានគរុកោសល្យខ្ពស់ ហើយគ្រូបង្រៀននឹងសម្បូរបែបនូវឯកសារ និងសម្ភារៈបន្ថែមទៀតក្នុងការបង្រៀនដល់និស្សិត។<br>- និស្សិត នឹងទទួលបាននូវការសិក្សាមួយប្រកបដោយគុណភាព ដោយមានសេវានិស្សិតគ្រប់គ្រាន់ដូចជាបណ្ណាល័យ បន្ទប់អនុវត្តន៍ ការប្រឹក្សាយោបល់បន្ថែមទៀត ហើយនិស្សិតនឹងជ្រើសរើសបាននូវជំនាញសមស្របទៅតាមទេពកោសល្យ ទៅតាមសមត្ថភាព និងទៅតាមតម្រូវការរបស់សង្គមជាតិ ព្រមទាំងមានឱកាសផ្លាស់ប្តូរការសិក្សា ទៅកាន់ដៃគូទាំងក្នុង និងក្រៅស្រុក។ |

## គោលដៅទី១ ៖ កម្មវិធីសិក្សា

កម្មវិធីសិក្សា គឺជាគោលដៅដ៏សំខាន់មួយនៃផែនការយុទ្ធសាស្ត្រទី៣ ស្តីពី ការរៀន និងការបង្រៀន។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិក និងភាគីដែលពាក់ព័ន្ធទាំងអស់របស់សាកលវិទ្យាល័យត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- រៀបចំគណៈកម្មការជំនាញមួយទៅតាមឯកទេសរៀងៗខ្លួន
- គណៈកម្មការជំនាញមួយត្រូវប្រជុំ សិក្សារៀបចំកម្មវិធីឱ្យស្របតាមបទដ្ឋានបច្ចេកទេស
- ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាតាមកាលកំណត់មួយច្បាស់លាស់។

## គោលដៅទី២ ៖ គ្រូបង្រៀន

គ្រូបង្រៀន គឺជាគោលដៅដ៏សំខាន់មួយទៀតនៃផែនការយុទ្ធសាស្ត្រទី៣ ស្តីពី ការរៀន និងការបង្រៀន។

គ្រូបង្រៀន គឺជាអ្នកដែលជួយ ឬបង្រៀនអ្នកផ្សេងទៀត។ គ្រូបង្រៀនតែងប្រើវិធីសាស្ត្រផ្សេងៗ ក្នុងការបង្រៀនតាមជំនាញ និងឯកទេសរបស់គាត់។ គ្រូបង្រៀន គឺជាវិស្វករនៃព្រលឹង។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិក និងភាគីដែលពាក់ព័ន្ធទាំងអស់របស់សាកលវិទ្យាល័យត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- រៀបចំនូវសម្ភារៈបរិក្ខារបច្ចេកវិទ្យាព័ត៌មាន (ICT)

- អភិវឌ្ឍន៍សមត្ថភាពដើម្បីឱ្យចេះប្រើ ICT ក្នុងការបង្រៀន ហើយត្រូវមានគរុកោសល្យក្នុងការផ្ទេរនូវចំណេះដឹង ហើយពេលបង្រៀន ត្រូវមានឯកសារ និងសម្ភារឧបទេសឱ្យបានគ្រប់គ្រាន់
- ជំរុញដល់ការផ្ទេរចំណេះដឹងប្រកបដោយប្រសិទ្ធភាព ឱ្យនិស្សិតងាយយល់ ងាយចងចាំ។

**គោលដៅទី៣ ៖ និស្សិត**

និស្សិត គឺជាគោលដៅចុងក្រោយ នៃផែនការយុទ្ធសាស្ត្រទី៣ ស្ដីពី ការរៀន និងការបង្រៀន។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិក និងភាគីដែលពាក់ព័ន្ធទាំងអស់របស់សាកលវិទ្យាល័យត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- រៀបចំសេវាផ្សេងៗដែលពាក់ព័ន្ធជាមួយការសិក្សា ដូចជា បណ្ណាល័យ បរិស្ថានថ្នាក់រៀន បន្ទប់ពិសោធន៍ (Lab) បច្ចេកវិទ្យាព័ត៌មាន (ICT) ឱ្យបានគ្រប់គ្រាន់
- ទំនាក់ទំនងដៃគូទាំងក្នុង និងក្រៅប្រទេស ដើម្បីបម្រើឱ្យការសិក្សាមួយដែលមានគុណភាព
- រៀបចំនូវគណៈកម្មការមួយប្រឹក្សាផ្តល់យោបល់ដល់និស្សិត ដើម្បីឱ្យនិស្សិតជ្រើសរើសបាននូវមុខជំនាញមួយត្រឹមត្រូវស្របតាមឧបនិស្ស័យរបស់ខ្លួន និងតាមតម្រូវការរបស់សង្គមជាតិ។

## យុទ្ធសាស្ត្រទី៤ ៖ ការងារនិស្សិត

ការងារនិស្សិតជាយុទ្ធសាស្ត្រទី៤ ដែលជាគោលដៅដ៏ចម្បងរបស់និស្សិតផងដែរ។ ការងារនិស្សិតសំដៅដល់អាជីព តួនាទី ឬមុខតំណែងក្នុងសង្គម ឬក្នុងស្ថាប័ន អង្គការ សមាគម ក្រុមហ៊ុន ។ល។ ដែលទទួលបានក្រោយពេលពួកគេបានបញ្ចប់ការសិក្សាដោយជោគជ័យ។ និស្សិតទទួលបានការងារច្រើន ឬអាចបង្កើតការងារដោយខ្លួនឯងបានច្រើន នោះគឺជាជោគជ័យរបស់សាកលវិទ្យាល័យ។ ការងារដែលល្អគឺជាការងារដែលស្របតាមជំនាញដែលនិស្សិតបានសិក្សា។ ដូចនេះ សាកលវិទ្យាល័យបានកំណត់ថាព័ត៌មានស្តីអំពីទំហំ ជំនាញ តម្រូវការ និងទីផ្សារការងារ ជាការងារស្នូល ដែលត្រូវយកចិត្តទុកដាក់ជាអាទិភាព ហើយការបង្កើតឱ្យមានការិយាល័យប្រឹក្សា និងសម្របសម្រួលការងារនិស្សិតរឹតតែចាំបាច់ថែមទៀត។

| យុទ្ធសាស្ត្រ | លទ្ធផលរំពឹងទុក |
|---|---|
| **ការងារនិស្សិត** | - តាមរយៈការិយាល័យទំនាក់ទំនងអន្តរជាតិ និងមុខរបរនឹងផ្តល់ព័ត៌មាន សម្រួលការងារជូនដល់ និស្សិត ដែលកំពុងបណ្តុះបណ្តាល និងបញ្ចប់ការបណ្តុះបណ្តាល<br>- សាកលវិទ្យាល័យ នឹងទទួលបាននូវព័ត៌មានស្តីអំពីតម្រូវការទីផ្សារមួយដែលត្រឹមត្រូវ និងច្បាស់លាស់ ដែលក្នុងនោះដឹងច្បាស់អំពីតម្រូវការ និងជំនាញជាមួយគ្នានោះដែរ សាកលវិទ្យាល័យ នឹងទទួលបាននូវផែនការបណ្តុះបណ្តាលមួយច្បាស់លាស់ ត្រឹមត្រូវស្របតាមតម្រូវការ និងទំហំការងារ។<br>- សាកលវិទ្យាល័យ នឹងមានដៃគូច្បាស់លាស់ក្នុងការទទួលនិស្សិតក្នុងពេលដែលបញ្ចប់ការសិក្សា ដែលក្នុងនោះមានទាំងក្នុងស្រុក និងក្រៅស្រុក។ |

## គោលដៅទី១ ៖ ផ្តល់ព័ត៌មាន និងការងារ

ផ្តល់ព័ត៌មាន និងការងារ គឺជាគោលដៅសំខាន់មួយនៃយុទ្ធសាស្ត្រទី៤ ស្តីពីការងារនិស្សិត។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិក និងភាគីដែលពាក់ព័ន្ធទាំងអស់របស់សាកលវិទ្យាល័យត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- រៀបចំយន្តការ នីតិវិធីសម្រាប់ផ្តល់ព័ត៌មានដល់និស្សិតឱ្យមានប្រសិទ្ធភាព ហើយដើរតួនាទីជាអ្នកជួយសម្របសម្រួលក្នុងការផ្តល់ការងារដល់និស្សិត
- ផ្តល់សេវាប្រឹក្សាយោបល់ផ្នែកការងារជូននិស្សិត
- ធ្វើការស្ទង់មតិ ស្តីពីព័ត៌មានទទួលបានការងាររបស់និស្សិតក្នុងកំឡុងពេលសិក្សា គ្រប់ពេលជិតបញ្ចប់ការសិក្សារបស់និស្សិតតាមកម្រិតនីមួយៗដើម្បីបង្កើតជារបាយការណ៍ផ្សេងៗ ងាយស្រួលរៀបផែនការបន្ត។

## គោលដៅទី២ ៖ តម្រូវការទីផ្សារ

តម្រូវការទីផ្សារ គឺជាតម្រូវការសំខាន់មួយ នៃយុទ្ធសាស្ត្រទី៤ ស្តីពីការងារនិស្សិត។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិក និងភាគីដែលពាក់ព័ន្ធទាំងអស់របស់សាកលវិទ្យាល័យត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ត្រូវសិក្សា កំណត់ឱ្យបានច្បាស់លាស់នូវទំហំនៃតម្រូវការការងាររបស់និស្សិត ដែលក្នុងនោះមានតម្រូវការនិស្សិតប្រចាំឆ្នាំ តាមជំនាញ ដើម្បីរៀបចំផែនការបណ្តុះបណ្តាលឱ្យត្រូវទៅនឹងតម្រូវការ
- រៀបចំជ្រើសរើសនិស្សិតដែលមានបំណងស្វែងរកការងារធ្វើ ដើម្បីត្រៀមដាក់ជូនទៅដៃគូពាក់ព័ន្ធ
- ចូលរួម និងផ្សព្វផ្សាយពីពិព័រណ៍ការងារ និងផលិតភាពជាតិទាំងខាងក្នុង និងជាមួយស្ថាប័នពាក់ព័ន្ធ។

## គោលដៅទី៣ ៖ ដៃគូទទួលនិស្សិត

ដៃគូនិស្សិត គឺជាគោលដៅដ៏សំខាន់មួយទៀតនៃផែនការយុទ្ធសាស្ត្រទី៤ ស្តីពីការងារនិស្សិត។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិក និងភាគីដែលពាក់ព័ន្ធទាំងអស់របស់សាកលវិទ្យាល័យត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- បង្កើតទំនាក់ទំនងជាមួយដៃគូទាំងក្នុងប្រទេស និងក្រៅប្រទេស ដើម្បីផ្តល់ឱកាសជូននិស្សិតក្នុងកម្មវិធីសិក្ខាសាលា វគ្គបណ្តុះបណ្តាល ចុះកម្មសិក្សា និងការស្វែងរកការងារធ្វើ
- ពង្រឹងទំនាក់ទំនងដៃគូដែលមានស្រាប់ និងបង្កើននូវការចុះអនុស្សារណៈយោគយល់គ្នាជាមួយដៃគូបន្ថែម ក្នុងការផ្តល់ឱកាសដល់និស្សិតចុះកម្មសិក្សា ផ្លាស់ប្តូរបទពិសោធន៍ ការស្រាវជ្រាវ និងឱកាសការងារ
- បង្កើតឱ្យមានក្រុមអតីតនិស្សិតសម្រាប់ជាច្រកក្នុងការទំនាក់ទំនងដៃគូ និងទទួលបាននូវព័ត៌មានថ្មីៗត្រលប់មកវិញ។

## យុទ្ធសាស្ត្រទី៥ ៖ ការស្រាវជ្រាវ

ការស្រាវជ្រាវជាយុទ្ធសាស្ត្រដ៏សំខាន់មួយទៀត សម្រាប់ដំណាក់កាលថ្មីមួយនេះ របស់សាកលវិទ្យាល័យ។ ការស្រាវជ្រាវ និងការរៀន ជាជើងឆ្វេងស្តាំរបស់និស្សិត។ ដូចគ្នានេះដែរ ការស្រាវជ្រាវ និងការបង្រៀន គឺជាបេះដូង និងខួរក្បាលរបស់គ្រូម្នាក់ៗ។ ដូចនេះការរៀន និងការបង្រៀនមិនអាចផ្តាច់ចេញពីការស្រាវជ្រាវបានទេ។ សាកលវិទ្យាល័យបានកំណត់ថា ធនធានស្រាវជ្រាវ អង្គភាពស្រាវជ្រាវ និងការបោះពុម្ពផ្សាយជាធាតុផ្សំបីសំខាន់សម្រាប់ជំរុញ និងអភិវឌ្ឍន៍វិស័យស្រាវជ្រាវឱ្យមានដំណើរការឡើង។

| យុទ្ធសាស្ត្រ | លទ្ធផលរំពឹងទុក |
|---|---|
| **ការស្រាវជ្រាវ** | - មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍នៃសាកលវិទ្យាល័យ នឹងទទួលបាននូវផែនការស្រាវជ្រាវមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយរៀបចំបាននូវក្រមសីលធម៌មួយ សម្រាប់អ្នកស្រាវជ្រាវ ដើម្បីឱ្យការស្រាវជ្រាវ និងប្រកបដោយវិជ្ជាជីវៈ។<br>- សាកលវិទ្យាល័យ នឹងទទួលបាននូវធនធានស្រាវជ្រាវគ្រប់គ្រាន់ ក្នុងនោះត្រូវមានធនធានថវិកា និងធនធានមនុស្ស។<br>- សាកលវិទ្យាល័យ នឹងទទួលបានការបោះពុម្ពផ្សាយនូវស្នាដៃវិទ្យាសាស្ត្រជាប្រចាំ ដែលមានគុណភាព ដោយមានការទទួលស្គាល់ពីមជ្ឈដ្ឋានខាងក្នុង និងខាងក្រៅ ក្នុងនោះមានទាំងទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ និងព្រឹត្តិបត្រស្រាវជ្រាវ តាមមហាវិទ្យាល័យ។ |

### គោលដៅទី១ ៖ មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ (RDC)

មជ្ឈមណ្ឌលស្រាវជ្រាវជាគោលដៅសំខាន់មួយនៃយុទ្ធសាស្ត្រទី៥ ស្តីពីការស្រាវជ្រាវ។

មជ្ឈមណ្ឌលស្រាវជ្រាវ គឺជាផ្នែកមួយនៃសាកវិទ្យាល័យ រៀបចំកសាងផែនការ និងសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិក និងភាគីដែលពាក់ព័ន្ធទាំងអស់របស់សាកលវិទ្យាល័យត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- រៀបចំឱ្យមានវគ្គបណ្តុះបណ្តាលទាំងខាងក្នុង និងខាងក្រៅជាមួយដៃគូលើការស្រាវជ្រាវ
- សិក្សារៀបចំឱ្យមានគោលការណ៍ផ្សេងៗ និងផែនការស្រាវជ្រាវរបស់ខ្លួន ដោយអញ្ជើញមហាវិទ្យាល័យ និងអង្គភាពពាក់ព័ន្ធ ប្រជុំគ្នា ដើម្បីជាត្រីវិស័យក្នុងការស្រាវជ្រាវ
- សហការរៀបចំឱ្យមានការចុះកម្មសិក្សា សម្រាប់ការស្រាវជ្រាវគ្រប់កម្រិតដោយសហការជាមួយគ្រប់មហាវិទ្យាល័យ និងដៃគូនានា។

### គោលដៅទី២ ៖ ធនធានស្រាវជ្រាវ

ធនធានស្រាវជ្រាវ គឺជាគោលដៅសំខាន់មួយទៀតនៃយុទ្ធសាស្ត្រទី៥ ស្តីពីការស្រាវជ្រាវ។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិក និងភាគីដែលពាក់ព័ន្ធទាំងអស់របស់សាកលវិទ្យាល័យត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- រៀបចំវគ្គសុក្រឹតការវិធីសាស្ត្រស្រាវជ្រាវដល់បុគ្គលិក គ្រូបង្រៀន និងនិស្សិត ដើម្បីឱ្យមានគុណវុឌ្ឍិគ្រប់គ្រាន់លើការងារស្រាវជ្រាវឱ្យមានគុណភាព
- រៀបចំគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃរាល់កិច្ចការស្រាវជ្រាវទាំងអស់ដើម្បីឱ្យធនធានស្រាវជ្រាវដែលផលិតមកមានគុណភាព និងស្របតាមការណែនាំត្រឹមត្រូវ
- ទំនាក់ទំនងស្វែងរកប្រភពថវិកាសម្រាប់គាំទ្រដល់គម្រោងស្រាវជ្រាវ និងស្វែងរកធនធានស្រាវជ្រាវពីដៃគូខាងក្រៅ។

### គោលដៅទី៣ ៖ ការបោះពុម្ពផ្សាយ

ការបោះពុម្ពផ្សាយ គឺជាគោលដៅចុងក្រោយនៃយុទ្ធសាស្ត្រទី៥ ស្តីពីការស្រាវជ្រាវ។

ដូចនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិក និងភាគីដែលពាក់ព័ន្ធទាំងអស់របស់សាកលវិទ្យាល័យត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- រៀបចំចេញផ្សាយទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រឱ្យបានជាប្រចាំ ដោយក្នុងមួយឆ្នាំចេញឱ្យបាន ២-៣ ដង ដោយជ្រើសរើសសម្រិតសម្រាំងអត្ថបទល្អៗ អត្ថបទបែបវិទ្យាសាស្ត្រក្នុងការចេញផ្សាយ
- ជំរុញលើការស្រាវជ្រាវ និងនិពន្ធអត្ថបទរបស់បុគ្គលិក គ្រូ និងនិស្សិត ដើម្បីចុះផ្សាយ
- មហាវិទ្យាល័យទាំងអស់ រួមទាំងសាលាក្រោយឧត្តម ត្រូវជំរុញ និងលើកទឹកចិត្តឱ្យមានផែនការក្នុងការចេញផ្សាយនូវព្រឹត្តិបត្រប្រចាំមហាវិទ្យាល័យរបស់ខ្លួន ហើយអត្ថបទទាំងឡាយសម្រាប់ចុះផ្សាយក្នុងអត្ថបទនេះអាចយកចេញពីនិស្សិតថ្មើម និងអាចយកចេញពីគ្រូដែលកំពុងបង្រៀន។

## យុទ្ធសាស្ត្រទី៦ ៖ ការកសាងសមត្ថភាព និងនវានុវត្តន៍ឌីជីថល

ការកសាងមូលធនមនុស្សឌីជីថល ចាប់ផ្តើមពីការកសាងសមត្ថភាពដល់គណៈគ្រប់គ្រង និងបុគ្គលិក ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលសម្រាប់បម្រើឱ្យការប្រើប្រាស់ការគ្រប់គ្រង និងការអភិវឌ្ឍសាកលវិទ្យាល័យឌីជីថល ឆ្លើយតបទៅនឹងតម្រូវការរបស់និស្សិត។ បន្ថែមលើនេះ ធនធានមនុស្សជំនាញបច្ចេកវិទ្យាឌីជីថលត្រូវទទួលបានការបណ្តុះបណ្តាល ដើម្បីជំរុញការអភិវឌ្ឍសាកលវិទ្យាល័យឌីជីថលប្រកបដោយប្រសិទ្ធភាព គុណភាព និងបរិយាបន្ន។ ទន្ទឹមនឹងនេះ ការលើកកម្ពស់អក្ខរកម្មឌីជីថលដល់សិស្ស និងនិស្សិត ជាអាទិភាពភាពចាំបាច់សម្រាប់ជំរុញការទទួលយក និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ការកាត់បន្ថយគម្លាតឌីជីថល ការបង្កើនភាពប្រកួតប្រជែង និងការប្រើប្រាស់សេវាសាកលវិទ្យាល័យឌីជីថល។

| យុទ្ធសាស្ត្រ | លទ្ធផលរំពឹងទុក |
|---|---|
| **ការកសាងសមត្ថភាព និងនវានុវត្តន៍ឌីជីថល** | - ទទួលបានមូលធនមនុស្សជំនាញឌីជីថល ដើម្បីគាំទ្របរិវត្តកម្មឌីជីថល និងអភិវឌ្ឍសាកលវិទ្យាល័យឌីជីថលមានសមត្ថភាពក្នុងការប្រកួតប្រជែងឌីជីថល<br>- មានហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធឌីជីថលប្រកបដោយទំនើបកម្មបច្ចេកវិទ្យាឌីជីថល សម្រាប់ |

| | |
|---|---|
| | គ្រប់គ្រង ផ្តល់សេវាអប់រំបណ្តុះបណ្តាល និងដើម្បីលើកកម្ពស់សកម្មភាពស្រាវជ្រាវ<br>- ទទួលបានសាកលវិទ្យាល័យឌីជីថលប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពជឿទុកចិត្ត។ |

**គោលដៅទី១ ៖ កសាងមូលធនឌីជីល**

កសាងមូលធនឌីជីល គឺជាគោលដៅសំខាន់មួយទៀតនៃយុទ្ធសាស្ត្រទី៦ ស្តីពីការកសាងសមត្ថភាព និងនវានុវត្តន៍ឌីជីថល។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- វាស់វែងកម្រិតសមត្ថភាព និងជំនាញបច្ចេកទេស ឌីជីថល ដោយបំពាក់សម្ភាររូបវន្តឱ្យបានគ្រប់គ្រាន់ពាក់ព័ន្ធនឹងការងារឌីជីថល ដើម្បីគាំទ្របរិវត្តកម្ម និងអភិវឌ្ឍន៍ឌីជីថល
- ជំរុញ និងរៀបចំកម្មវិធីបណ្តុះបណ្តាលឌីជីថល ដល់គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យ-គ្រូ និងនិស្សិត ដើម្បីបញ្ជ្រាបការយល់ដឹង ពីមូលដ្ឋានបច្ចេកវិទ្យា និងការប្រើប្រាស់ឌីជីថល
- កំណត់ស្តង់ដាគុណវុឌ្ឍិ សមត្ថភាព និងជំនាញបច្ចេកវិទ្យាឌីជីថលសំខាន់ៗ និងរៀបចំកម្មវិធីតម្រង់ទិស ផ្សព្វផ្សាយ ជំរុញ និងលើកទឹកចិត្តដល់សិស្សានុសិស្ស និងនិស្សិត ឱ្យចាប់យកការសិក្សាជំនាញបច្ចេកវិទ្យាឌីជីថល ឱ្យកាន់តែច្រើន ដើម្បីបង្កើន អ្នកជំនាញឌីជីថល ក្នុងទីផ្សារការងារ។

**គោលដៅទី២ ៖ លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល**

លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល គឺជាគោលដៅសំខាន់ចុងក្រោយនៃយុទ្ធសាស្ត្រទី៦ ស្តីពីការកសាងសមត្ថភាព និងនវានុវត្តន៍ឌីជីថល។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ជំរុញការបង្កើតប្រព័ន្ធស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាឌីជីថល
- ជំរុញការផ្ទេរ និងចែករំលែកចំណេះដឹងបច្ចេកវិទ្យាឌីជីថលតាមរយៈការរៀបចំកិច្ចសហការ និងការអនុវត្តគម្រោងរួមគ្នារវាងអង្គភាព ស្ថាប័ន និងគ្រឹះស្ថានឧត្តមសិក្សា
- ជំរុញសហគ្រិនភាពនៃនវានុវត្តន៍ឌីជីថល ដោយរៀបចំយន្តការទទួលស្គាល់នវានុវត្តន៍ថ្មីៗ កម្មវិធីប្រកួតប្រជែង និងការការពារកម្មសិទ្ធិបញ្ញាដល់និស្សិត ដើម្បីឱ្យនិស្សិតយកទៅប្រើប្រាស់ក្នុងវិស័យសាធារណៈ និងឯកជន និងជានាឧត្តមភាពប្រកួតប្រជែងឌីជីថល។

**គោលដៅទី៣ ៖ ការរៀបចំកិច្ចសហការនិងភាពជាដៃគូជាមួយស្ថាប័នបច្ចេកវិទ្យាឌីជីថល**

ការរៀបចំកិច្ចសហការនិងភាពជាដៃគូជាមួយស្ថាប័នបច្ចេកវិទ្យាឌីជីថល គឺជាគោលដៅសំខាន់មួយទៀតនៃយុទ្ធសាស្ត្រទី៦ ស្តីពីការកសាងសមត្ថភាព និងនវានុវត្តន៍ឌីជីថល។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ បុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- រៀបចំវេទិការវាងក្រុមប្រឹក្សាវិទ្យាសាស្ត្រ និងស្ថាប័នឌីជីថល ដើម្បីផ្តល់សេវា និងដំណោះស្រាយបច្ចេកទេស សម្រាប់សាកលវិទ្យាល័យឌីជីថល
- ជំរុញការផ្សព្វផ្សាយ សម្របសម្រួល និងលើកទឹកចិត្តស្ថាប័នឌីជីថល តាមរយៈការចូលរួមអភិវឌ្ឍន៍ និងផ្គត់ផ្គង់ការរៀបចំប្រព័ន្ធ និងសេវាបច្ចេកវិទ្យាឌីជីថល ដើម្បីកៀរគរធនធានមនុស្ស
- ជំរុញកិច្ចសហប្រតិបត្តិជាមួយអ្នកបច្ចេកទេសក្នុងវិស័យបច្ចេកវិទ្យាឌីជីថល តាមរយៈការផ្តល់សេវាសាកលវិទ្យាល័យឌីជីថល ការបញ្ជាក់ការសិក្សា ការបញ្ជាក់ព្រឹត្តិបត្រពិន្ទុ ការបញ្ជាក់វិញ្ញាបនបត្របណ្តោះអាសន្ន ការបង់ថ្លៃសិក្សា និងការបង់ថ្លៃសេវាផ្សេងៗ ដើម្បីបម្រើដល់សេវានិស្សិតឱ្យកាន់តែប្រសើរ។

## ៦. ធនធានហិរញ្ញវត្ថុ

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០២៣-២០២៧) នេះ ធនធានហិរញ្ញវត្ថុដើម្បីគាំទ្រដល់ផែនការសកម្មភាពប្រចាំឆ្នាំនីមួយៗ គឺមួយផ្នែកទទួលបានពីដៃគូសហការដែលក្នុងនោះមានក្រសួងអប់រំ យុវជន និងកីឡា ដៃគូសហការដែលបានចុះ MoU ជាមួយគ្នា និងមួយផ្នែកធំជាបន្ទុករបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប។

## ៧. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ចំពោះការតាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពផ្អែកលើយុទ្ធសាស្ត្រ គឺធ្វើឡើងជារៀងរាល់ឆមាស និងឆ្នាំ។

## ៨. សន្និដ្ឋាន

ដោយផ្អែកលើយុទ្ធសាស្ត្រ និងគោលដៅដូចបានជម្រាបជូនខាងលើ អាចឱ្យយើងឃើញថាសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប មានឱកាស និងសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រែក្លាយជាសាកលវិទ្យាល័យឌីជីថលដែលអាចស្រូបយកនិស្សិតឱ្យចុះឈ្មោះចូលរៀនតាមផែនការជារៀងរាល់ឆ្នាំ ជាពិសេស សាកល-វិទ្យាល័យមានបទពិសោធន៍ មានធនធានមនុស្ស មានសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ សម្ភារៈសម្ភារបែបក្នុងការសិក្សានិងការស្រាវជ្រាវ ជាពិសេសមានមូលដ្ឋានធនធានហិរញ្ញវត្ថុរឹងមាំ។

ថ្ងៃចន្ទ ៥រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា គ.ស. ២០២៣
**ប្រធានក្រុមប្រឹក្សាភិបាល**

ឧកញ៉ាបណ្ឌិត **ឡុង លាង**

បានយកសេចក្តីគោរពជូន
ឯកឧត្តមឧកញ៉ាបណ្ឌិតប្រធានក្រុមប្រឹក្សាភិបាលសូមហត្ថលេខា
ថ្ងៃសុក្រ ២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមេសា គ.ស. ២០២៣
**សាកលវិទ្យាធិការ**

**ស៊ុន សេដ្ឋា**